កម្មវិធីគាំទ្រកុមាររដ្ឋរបស់វ៉ាស៊ីនតោន



បង្កើតខ្សែស្រឡាយសម្រាប់ជាប្រយោជន៍កូនរបស់អ្នកឬ

# អ្វីដែលឪពុក ឬម្តាយគ្រប់រូបគួរដឹង

មាតាបិតាគ្រប់រូបគួរចូលរួមចំណែកដល់តម្រូវការរបស់កូនរបស់ពួកគេ។ កុមារគ្រប់រូបសមនឹងស្គាល់ឪពុកម្តាយស្របច្បាប់របស់គាត់ ឬនាង និងដើម្បីទាមទារសិទ្ធិ និងអត្ថប្រយោជន៍ដែលមកជាមួយចំណេះដឹងនេះ។

Washington State
Department of Social & Health Services
Transforming lives

## តើហេតុអ្វីខ្ញុំគួរបង្កើតខ្សែស្រឡាយ?

វាគឺចាំបាច់បង្កើតទំនាក់ទំនងស្របច្បាប់រវាងឪពុកម្ដាយ និងកូន។

ការកំណត់ឪពុកម្ដាយស្របច្បាប់ផ្ដល់អត្ថប្រយោជន៍ដល់កូន។ អត្ថប្រយោជន៍ទាំងនេះគឺមាន៖

- អត្ថប្រយោជន៍រដ្ឋាភិបាល ដូចជាសន្តិសុខសង្គម និងអត្ថប្រយោជន៍អ្នកក្នុងបន្ទុករបស់អតីតយុទ្ធជន អាចរកបានសម្រាប់កុមារ។
- ធានារ៉ាប់រងថែទាំសុខភាពសម្រាប់កុមារអាចរកបានតាមរយៈ: គម្រោងសុខភាពរបស់ឪពុកម្ដាយ។
- គោលការណ៍ធានារ៉ាប់រងអាយុជីវិត និងអត្ថប្រយោជន៍មរតកដទៃទៀតគឺអាចរកបាន។
- វេជ្ជបណ្ឌិតគ្រួសារអាចជួយកុមារកាន់តែប្រសើរ នៅពេលពួកគេស្គាល់ប្រវត្តិវេជ្ជសាស្រ្តគ្រួសាររបស់កុមារពេញលេញ។
- ឪពុកម្ដាយផ្ដល់ការគាំទ្រដល់អារម្មណ៍ និងហិរញ្ញវត្ថុ។

## តើខ្ញុំអាចបង្កើតខ្សែស្រឡាយដោយរបៀបណា?

មានវិធីមួយចំនួនដើម្បីបង្កើតខ្សែស្រឡាយស្របច្បាប់។

- **ការរៀបការ ឬភាពជាដៃគូក្នុងគ្រួសារដោយចុះបញ្ជី**

  បើកុមារកើតអំឡុងពេលរៀបការ ឬជាភាពដៃគូក្នុងគ្រួសារដោយបានចុះបញ្ជី កុមារត្រូវបានសន្មតជាកូននៃការរៀបការ ឬភាពជាដៃគូក្នុងគ្រួសារនោះ។ នេះបង្កើត “ការសន្មតនៃខ្សែស្រឡាយ”។ ការសន្មតមួយអាចត្រូវបានយកឈ្នះដោយការទទួលស្គាល់ដែលបានរៀបចំដោយត្រឹមត្រូវនៃខ្សែស្រឡាយ ឬដីកាតុលាការ។

- **ការទទួលស្គាល់នូវខ្សែស្រឡាយ**

  ការទទួលស្គាល់នូវខ្សែស្រឡាយគឺជាទម្រង់ស្របច្បាប់ដែលអនុញ្ញាតខ្សែស្រឡាយឱ្យត្រូវបានបង្កើតឡើងដោយស្ម័គ្រចិត្តដោយមិនបាច់ឡើងតុលាការ។ ការទទួលស្គាល់នូវខ្សែស្រឡាយគឺត្រូវបានចុះហត្ថលេខាដោយឪពុកម្ដាយបង្កើតរបស់កុមារ និងបុគ្គលម្នាក់ដែលចង់បង្កើតខ្សែស្រឡាយ។ ពាក្យសុំនេះអាចចុះហត្ថលេខាដោយឪពុក ឬម្ដាយដែលអះអាងហ្សែនដូចគ្នា ឪពុក ឬម្ដាយដែលបានសន្មត ឬឪពុក ឬម្ដាយតាមរយៈជំនួយការបន្តពូជ។ ច្បាប់រដ្ឋចាត់ទុកបុគ្គលម្នាក់ៗដែលចុះហត្ថលេខាលើពាក្យសុំនេះឱ្យក្លាយជាឪពុក ឬម្ដាយស្របច្បាប់របស់កុមារ។ ទាំងឪពុកម្ដាយបង្កើត និងអ្នកផ្សេងទៀតដែលចង់ឱ្យគេបង្កើតខ្សែស្រឡាយត្រូវតែចុះហត្ថលេខាលើពាក្យសុំ ហើយវាត្រូវតែបានទទួលស្គាល់ ឬចុះហត្ថលេខានៅចំពោះមុខសាក្សី។ វាត្រូវតែបានដាក់ជាមួយមជ្ឈមណ្ឌលស្ថិតិសុខភាព (DOH/CHS) ៍នក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន។ មន្ទីរពេទ្យនានាអាចផ្ដល់ពាក្យសុំ និងព័ត៌មានសេវាមេធាវី ឬសាក្សី និងផ្ញើពាក្យសុំទៅ DOH/CHS សម្រាប់អ្នក។ DOH/CHS ក៏ងដាក់ឈ្មោះឪពុក ឬម្ដាយដែលចុះហត្ថលេខាលើពាក្យសុំជាឪពុក ឬម្ដាយស្របច្បាប់លើសំបុត្រកំណើត។

- **ដីកាតុលាការ**

  ក្រៅពីការទទួលស្គាល់ដោយស្ម័គ្រចិត្តនូវខ្សែស្រឡាយ តុលាការកំណត់ខ្សែស្រឡាយស្របច្បាប់។

# ការបង្កើតខ្សែស្រឡាយដោយប្រើពាក្យសុំការ ទទួលស្គាល់នូវខ្សែស្រឡាយ

## ហេតុអ្វីខ្ញុំគួរចុះហត្ថលេខាលើឯកសារទទួលស្គាល់នូវ ខ្សែស្រឡាយ

ពាក្យសុំគឺមានតម្លៃទាប ជាវិធីស្របច្បាប់ដើម្បីបង្កើត ខ្សែស្រឡាយ។ សូមចុះហត្ថលេខាលើពាក្យសុំតែបើអ្នកប្រាកដថាអ្នកចង់ក្លាយជាឪពុក ឬម្តាយស្របច្បាប់របស់កុមារ។

## តើខ្ញុំអាចចុះហត្ថលេខាពាក្យសុំទទួលស្គាល់មាតាបិតានៅឯណា?

ឪពុកម្តាយភាគច្រើនចុះហត្ថលេខាលើពាក្យសុំនៅមន្ទីរពេទ្យ គ្លីនិកសម្ភព ឬនៅផ្ទះក្រោមការថែទាំរបស់ឆ្មប។

- ប្រសិនបើអ្នកត្រូវការជំនួយ មន្ទីរពេទ្យ ឆ្មប ឬគ្លីនិកសម្ភព បុគ្គលិកអាចឆ្លើយតបសំណួររបស់អ្នកបាន ជួយអ្នកបំពេញពាក្យសុំ មេធាវី ឬសាក្សីពាក្យសុំ ហើយផ្ញើពាក្យសុំទៅ DOH/CHS។ ការិយាល័យ DCS ធនាគារ និងនាយកដ្ឋានសុខភាពក្នុងតំបន់ក៏អាចជាមេធាវី ឬសាក្សីពាក្យសុំ។
- ប្រសិនបើអ្នកចុះហត្ថលេខាលើពាក្យសុំទទួលស្គាល់នូវខ្សែស្រឡាយក្នុងពេលកុមារមានអាយុ 5 ថ្ងៃ អ្នកនឹងមិនត្រូវការចំនាយថ្លៃសេវាពាក្យសុំទេ។
- ប្រសិនបើអ្នកមិនចុះហត្ថលេខានៅមន្ទីរពេទ្យទេ អ្នកអាចយកពាក្យសុំនៅក្រសួងសុខាភិបាលខោនធីក្នុងតំបន់របស់អ្នក ឬការិយាល័យផ្នែកគាំទ្រកុមារ (DCS) ណាមួយ។ បុគ្គលិក DCS អាចធ្វើសាក្សី ឬមេធាវីពាក្យសុំ។ បើអ្នកចុះហត្ថលេខានៅការិយាល័យ DCS, DCS នឹងផ្ញើពាក្យសុំឱ្យបំពេញ និងចំណាយថ្លៃសេវាបំពេញ។ ទូរស័ព្ទទៅ DCS តាមលេខ 800-442-KIDS (5437) និងស្នើសុំផ្ញើពាក្យសុំទៅអ្នក។

## តើខ្ញុំអាចស្នើសុំច្បាប់ចម្លងនៃពាក្យសុំទទួលស្គាល់នូវខ្សែស្រឡាយបានដែរទេ?

បាទ។ ក្រសួងសុខាភិបាល (DOH) ដំណើរការ និងរក្សាកំណត់ត្រាផ្លូវការនៃពាក្យសុំទទួលស្គាល់នូវខ្សែស្រឡាយ។ អ្នកអាចបោះពុម្ពទម្រង់បញ្ហាមួយនៅ www.doh.wa.gov ដើម្បីបញ្ជាលិខិតផ្ទៀងផ្ទាត់ខ្សែស្រឡាយ ឬច្បាប់ចម្លងពាក្យសុំខ្សែស្រឡាយដែលអនុវត្តបាន។ ទូរស័ព្ទទៅ DOH/CHS តាមលេខ 360-236-4300 នូវសំណួរណាមួយ។ ថ្លៃសេវាដំណើរការ DOH ត្រូវអនុវត្ត។

## តើសិទ្ធិស្របច្បាប់របស់ខ្ញុំមានអ្វីខ្លះ នៅពេលខ្ញុំចុះហត្ថលេខាពាក្យសុំការទទួលស្គាល់នូវខ្សែស្រឡាយ?

នៅពេលអ្នកចុះហត្ថលេខាពាក្យសុំ ច្បាប់សហព័ន្ធនិយាយថា អ្នកត្រូវតែទទួលទាំងព័ត៌មានជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់អំពីសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក។ សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នកគឺរួមបញ្ចូលនៅទំព័រទី 2 នៃពាក្យសុំខាងក្រោមសេចក្តីថ្លែងការណ៍ការទទួលស្គាល់។ វាចាំបាច់អ្នកត្រូវយល់ពីអ្វីដែលវានិយាយ។ អានសេចក្តីថ្លែងការណ៍ ហើយធ្វើមួយខាងក្រោម ៖

- មើលវីដេអូនៅមន្ទីរពេទ្យ គ្លីនិកសម្ភព ទាយកដ្ឋានសុខភាពក្នុងតំបន់របស់អ្នក ឬនៅការិយាល័យ DCS ណាមួយ។
- ស្តាប់ព័ត៌មានការទទួលស្គាល់នូវខ្សែស្រឡាយដោយស្វ័យប្រវត្តិដោយទូរស័ព្ទទៅលេខ 800-356-0463។
- ស្នើឱ្យនរណាម្នាក់អានសេចក្តីថ្លែងការណ៍ឱ្យអ្នក។
- **កុំចុះហត្ថលេខាលើពាក្យសុំ រហូតទាល់អ្នកទទួល និងយល់ដឹងទាំងព័ត៌មានជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់។**

## តើខ្ញុំអាចចុះហត្ថលេខាលើការទទួលស្គាល់នូវខ្សែស្រឡាយសូម្បីតែខ្ញុំអាយុក្រោម 18 ឆ្នាំ?

បាទ។ ការទទួលស្គាល់នូវខ្សែស្រឡាយដែលបានចុះហត្ថលេខាដោយអនីតិជនគឺស្របច្បាប់។ ច្បាប់រដ្ឋចែងថា អនីតិជន (មនុស្សអាយុក្រោម 18 ឆ្នាំ) ដែលចុះហត្ថលេខាលើពាក្យសុំមានកម្រិតទំនួលខុសត្រូវស្មើនឹងមនុស្សពេញវ័យដែរ។

## ចុះបើខ្ញុំមិនច្បាស់ថាខ្ញុំចង់ចុះហត្ថលេខាលើពាក្យសុំការទទួលស្គាល់នូវខ្សែស្រឡាយ?

ចុះហត្ថលេខាលើពាក្យសុំ ប្រសិនបើអ្នកដឹងច្បាស់ថា អ្នកចង់បង្កើតដោយស្របច្បាប់ថាអ្នកជាឪពុក ឬម្តាយរបស់កុមារ។ អ្នកប្រហែលជាចង់និយាយទៅកាន់មេធាវី។ ប្រសិនបើអ្នកសម្រេចចិត្តថាមិនចុះហត្ថលេខាទទួលស្គាល់ទេ មានវិធីច្រើនទៀតដើម្បីបង្កើត ខ្សែស្រឡាយ។ អ្នកអាចស្នើឱ្យតុលាការបង្កើតខ្សែស្រឡាយ។ ប្រសិនបើអ្នកមានសំណួរអំពីការបង្កើតខ្សែស្រឡាយ អ្នកអាចទូរស័ព្ទទៅ DCS។ DCS មិនអាចផ្តល់ដំបូន្មានស្របច្បាប់ទេ។

DCS មិនមានកម្មវិធីតេស្តបិតុភាពឥតគិតថ្លៃនោះទេ។ មនុស្សភាគច្រើនចង់បានកម្មវិធីនេះពីមន្ទីរពេទ្យដែលកុមារកើត។ ប្រសិនបើអ្នកចង់ដឹងថាបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សូមទាក់ទងកម្មវិធីតេស្តបិតុភាពស្ម័គ្រចិត្ត DCS (VPTP) តាមលេខ 1-800-285-1892។

## តើខ្ញុំអាចប្តូរចិត្តរបស់ខ្ញុំទេ បន្ទាប់ពីខ្ញុំចុះហត្ថលេខាលើពាក្យសុំ?

ទាំងឪពុក ឬម្តាយដែលបានចុះហត្ថលេខាលើពាក្យសុំទទួលស្គាល់នូវ ខ្សែស្រឡាយ ឬបុគ្គលដែលបានចុះហត្ថលេខាសេចក្តីបដិសេធនូវ ខ្សែស្រឡាយ អាចប្តូរចិត្តរបស់ពួកគេបន្ទាប់ពីចុះហត្ថលេខា។ ពាក្យស្របច្បាប់សម្រាប់ឈ្មោះរបស់អ្នកដែលបានដកចេញពីកំណត់ត្រាកំណើតគឺ បោះបង់។ អ្នកត្រូវតែបំពេញពាក្យសុំបោះបង់នូវខ្សែស្រឡាយ និងដាក់បណ្តឹងវាជាមួយមជ្ឈមណ្ឌលស្ថិតិសុខភាព នៃក្រសួងសុខាភិបាលដើម្បីបោះបង់ការទទួលស្គាល់ ឬបដិសេធក្នុងពេលច្រើនបំផុត 60 ថ្ងៃបន្ទាប់ថ្ងៃ DOH/CHS ដាក់បណ្តឹងពាក្យសុំ ឬមុនពេលបណ្តឹងសវនាការជាមុន មួយណាដែលកើតឡើងមុន។ អ្នកនឹងត្រូវរបង់ថ្លៃសេវាបណ្តឹង ពាក្យសុំបោះបង់នូវខ្សែស្រឡាយជាមួយ DOH/CHS។

## តើខ្ញុំត្រូវតែផ្តល់មេធាវីដើម្បីបោះបង់ការទទួលស្គាល់នូវខ្សែស្រឡាយ?

អ្នកដាក់បណ្តឹងពាក្យសុំបោះបង់នូវខ្សែស្រឡាយដោយខ្លួនឯង ឬជាមួយជំនួយពីការដាក់បណ្តឹងពាក្យសុំបោះបង់នូវខ្សែស្រឡាយ DOH/CHS នឹងយកចេញឈ្មោះរបស់ឪពុក ឬម្តាយទីពីរចេញពីសំបុត្រកំណើត។

## ចុះបើខ្ញុំប្តូរចិត្ត ហើយ 61 ថ្ងៃ ឬលើសនេះបន្ទាប់ថ្ងៃដែល DOH/CHS ដាក់បណ្តឹងទទួលស្គាល់?

ទាំងឪពុក ឬម្តាយអាចប្រជែងការទទួលស្គាល់នូវខ្សែស្រឡាយក្នុងតុលាការ។ ការបដិសេធនូវខ្សែស្រឡាយក៏អាចប្រជែងគ្នាក្នុងតុលាការដែរ។ ប្រសិនបើអ្នកដាក់បណ្តឹងសកម្មភាពប្រឆាំងនឹងការទទួលស្គាល់ ឬការបដិសេធ មានហេតុផលមានកំណត់ដែលតុលាការនឹងស្តាប់ករណីរបស់អ្នក អ្នកប្រហែលត្រូវតែផ្តល់ហត្ថលេខាការទទួលស្គាល់ ឬការបដិសេធ ដោយសារការបន្លំការបង្ខំ ឬកំហុសការពិត។ អ្នកមានពេល 4 ឆ្នាំ ដើម្បីចាប់ផ្តើមសកម្មភាពប្រជែងប្រឆាំងនឹងការទទួលស្គាល់នូវខ្សែស្រឡាយ ឬការបដិសេធនូវខ្សែស្រឡាយក្នុងតុលាការពីថ្ងៃដាក់បណ្តឹងជាមួយ DOH/CHS។

### តើមានអ្វីកើតឡើង បើឪពុក ឬម្តាយបង្កើតរៀបការនឹងអ្នកផ្សេង ឬក្នុងភាពជាដៃគូក្នុងគ្រួសារដោយមានចុះបញ្ជី?

បើឪពុក ឬម្តាយបង្កើតរៀបការ ឬក្នុងភាពជាដៃគូក្នុងគ្រួសារដោយមានចុះបញ្ជី អំឡុងពេលមានផ្ទៃពោះ ប្តី ឬប្រពន្ធ ឬដៃគូគ្រួសារត្រូវបានសន្មត (ជឿថា) ក្លាយជាឪពុក ឬម្តាយផ្សេងទៀត បើកុមារកើត ៖

- អំឡុងពេលរៀបការ ឬក្នុងការចុះបញ្ជីភាពជាដៃគូក្នុងគ្រួសារ
- ក្នុងពេល 300 ថ្ងៃបន្ទាប់ពីបញ្ចប់ការរៀបការ ឬក្នុងភាពជាដៃគូក្នុងគ្រួសារដោយមានចុះបញ្ជី។

ប្រសិនបើប្តី ឬប្រពន្ធ ឬដៃគូគ្រួសាររបស់ឪពុក ឬម្តាយបង្កើតយល់ព្រមឱ្យអ្នកផ្សេងចុះហត្ថលេខាជាឪពុក ឬម្តាយទីពីរ បុគ្គលនោះអាចចុះហត្ថលេខាការទទួលស្គាល់នូវខ្សែស្រឡាយ។ ប្តី ឬប្រពន្ធ ឬដៃគូគ្រួសាររបស់ឪពុក ឬម្តាយបង្កើតត្រូវតែចុះហត្ថលេខាបដិសេធនូវខ្សែស្រឡាយ ឬការទទួលស្គាល់នូវខ្សែស្រឡាយគឺមិនស្របច្បាប់។

## ការបង្កើតខ្សែស្រឡាយក្នុងតុលាការ

### នៅពេលណាគួរតែតុលាការបង្កើតខ្សែស្រឡាយ?

អ្នកគួរតែទៅតុលាការ នៅពេលអ្នកជឿថាមានឪពុក ឬឪពុកម្តាយអាចទៅរួចដទៃ។

### ហេតុផលផ្សេងទៀតសម្រាប់ប្រើតុលាការដើម្បីបង្កើតខ្សែស្រឡាយ៖

- បើឪពុក ឬម្តាយគឺមិនច្បាស់លាស់អំពីការចុះហត្ថលេខាការទទួលស្គាល់។
- បើប្តី ឬប្រពន្ធ ឬដៃគូគ្រួសាររបស់ឪពុក ឬម្តាយបង្កើតគឺមិនមានឆន្ទៈចុះហត្ថលេខាការបដិសេធ។



## តើខ្ញុំបើកករណីខ្សែស្រឡាយមួយក្នុងតុលាការដោយរបៀបណា?

រដ្ឋអាចបង្កើតខ្សែស្រឡាយសម្រាប់កូនរបស់អ្នក បើអ្នកដាក់ពាក្យសុំបើកករណីបង្កើតនូវខ្សែស្រឡាយជាមួយ DCS ។ ទូរស័ព្ទទៅ DCS តាមលេខ 800-442-KIDS (5437) ឬការិយាល័យ ឌជស៊ ដែលនៅជិតបំផុតសម្រាប់ព័តមានបន្ថែម។

ប្រសិនបើ DCS ទទួលបានករណីរបស់អ្នក យើងនឹងយោងករណីរបស់អ្នកដល់ទៅមេធាវីកាត់ក្តី។ ព្រះរាជអាជ្ញាដើរតួក្នុងនាមកូនរបស់អ្នក ហើយមិនអាចតំណាងអ្នកក្នុងតុលាការ ឬផ្តល់ដំបូន្មានស្របច្បាប់ឡើយ។ ព្រះរាជអាជ្ញាអាចឆ្លើយសំណួរទូទៅអំពីករណីខ្សែស្រឡាយរបស់អ្នក។ អ្នកត្រូវតែប្រាប់យើង បើកូនរបស់អ្នកកំពុងទទួលជំនួយសាធារណៈ ឬជំនួយវេជ្ជសាស្ត្រ។

DCS ក៏ចូលប្រើតុលាការកុលសម្ព័ន្ធដើម្បីបង្កើតករណីកុលសម្ព័ន្ធជាក់លាក់។

អ្នកគួរតែស្នើមេធាវីម្នាក់សម្រាប់ឆ្លើយសំណួរស្របច្បាប់ និងសម្រាប់តំណាងក្នុងតុលាការ។ បើអ្នកមិនចង់បានសេវាកម្ម DCS ទេ អ្នក ឬមេធាវីរបស់អ្នកអាចដាក់បណ្តឹងសកម្មភាពខ្សែស្រឡាយជាមួយតុលាការដែលមានយុត្តាធិការលើករណីរបស់អ្នក។

## តើខ្ញុំបង្កើតខ្សែស្រឡាយក្នុងតុលាការដោយរបៀបណា?

ប្រសិនបើរដ្ឋកំពុងព្យាយាមបង្កើតខ្សែស្រឡាយ ព្រះរាជអាជ្ញាខោនធីនឹងបម្រើក្រដាសស្របច្បាប់ជាធម្មតាលើឪពុកដែលអាចទៅរួច ឬឪពុកម្តាយអាចទៅរួចដទៃ។ ព្រះរាជអាជ្ញា ឬតុលាការអាចតម្រូវឱ្យម្តាយ ឪពុកអាចទៅរួច និងកុមារឱ្យធ្វើតេស្តហ្សែន។ តុលាការអាចបញ្ចូលដីកាការបង្កើតនូវខ្សែស្រឡាយ។

## តើអ្វីជាការធ្វើតេស្តហ្សែន ហើយតើខ្ញុំត្រូវតែឱ្យគេធ្វើតេស្តឱ្យដែរទេ?

ហ្សែនគឺជាផ្នែកជាលិការាងកាយរបស់យើង។ ពួកវាបញ្ជូនលក្ខណៈនានាពីឪពុកម្តាយទៅកូនរបស់ពួកគេ។ ការធ្វើតេស្តហ្សែនប្រៀបធៀបហ្សែន។ បើហ្សែនជាក់ស្តែងត្រូវគ្នា ឪពុក ឬម្តាយ និងកូនជាប់សាច់ឈាមគ្នា។ ការធ្វើតេស្តហ្សែនសម្រាប់បិតុភាពគឺត្រឹមត្រូវ។

ការធ្វើតេស្តហ្សែនសម្រាប់បិតុភាពប្រៀបធៀបផ្នែកខុសគ្នានៃជាលិការបស់ឪពុក របស់ម្តាយ និងរបស់ដែលបានប្រមូលដោយត្បារខាងក្នុងមាត់របស់ពួកគេ។ មន្ទីរពិសោធន៍ធ្វើតេស្តហ្សែនចេញរបាយការណ៍ពន្យល់ថាតើបុរសទំនងជាឪពុកតាមជីវសាស្ត្រ។ តុលាការជាញឹកញាប់តម្រូវការធ្វើតេស្តហ្សែន បើមានឪពុកច្រើនជាងមួយអាចទៅរួច។

### តើមានថ្លៃចំណាយដែរទេក្នុងការបង្កើតខ្សែស្រឡាយនៅក្នុងតុលាការដែរទេ?

- ប្រសិនបើព្រះរាជអាជ្ញាខោនធីបង្កើតខ្សែស្រឡាយក្នុងតុលាការលើករណី DCS អ្នកមិនចំណាយថ្លៃដាក់ឯកសារឡើយ។ អាចមានថ្លៃសេវាផ្សេងទៀតពាក់ព័ន្ធនឹងការបង្កើតខ្សែស្រឡាយក្នុងតុលាការ
- ប្រសិនបើអ្នកជួលមេធាវីម្នាក់ អ្នកទទួលខុសត្រូវថ្លៃសេវា និងថ្លៃតុលាការ។
- តុលាការអាចបញ្ជាឱ្យឪពុកម្ដាយចំណាយថ្លៃធ្វើតេស្តហ្សែន ឬថ្លៃតុលាការផ្សេងទៀត។

## រឿងច្រើនទៀតដែលអ្នកត្រូវដឹង

### តើខ្ញុំបង្កើតសិទ្ធិឪពុកម្ដាយ ដូចជាសិទ្ធិធ្វើអាណាព្យាបាល និងការសួរសុខទុក្ខ?

មានតែតុលាការប៉ុណ្ណោះអាចដោះស្រាយបញ្ហា សិទ្ធិធ្វើអាណាព្យាបាល និងការសួរសុខទុក្ខ។ នេះគឺរួចរាល់ជាមួយកាលវិភាគគម្រោង/លំនៅដ្ឋានឪពុកម្ដាយ។ ប្រសិនបើអ្នក និងឪពុកម្ដាយផ្សេងទៀតមិនអាចសម្រេចចិត្តលើសិទ្ធិធ្វើអាណាព្យាបាល និងការសួរសុខទុក្ខ ទាក់ទងមេធាវី អ្នកសម្របសម្រួល ឬអ្នកសម្របសម្រួលតុលាការ។

- ដើម្បីនិយាយជាមួយអ្នកសម្របសម្រួល។ ទូរស័ព្ទទៅមជ្ឈមណ្ឌលដំណោះស្រាយជម្លោះវ៉ាស៊ីនតោន តាមលេខ 800-280-4770។
- ដើម្បីស្វែងរកអ្នកសម្របសម្រួលតុលាការ ទាក់ទងការិយាល័យរបស់ស្មៀនតុលាការកំពូលក្នុងតំបន់របស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម ទូរស័ព្ទទៅ DCS ហើយស្នើសុំខិត្តប័ណ្ណមានចំណងជើងថា “តើខ្ញុំអាចធ្វើអ្វី ដើម្បីខ្ញុំអាចឃើញកូនរបស់ខ្ញុំ ឬឃើញពួកគេញឹកញាប់ជានេះ? ផ្នែកគាំទ្រកុមារ ការសួរសុខទុក្ខ និងសិទ្ធិធ្វើអាណាព្យាបាល។”

### តើខ្ញុំអាចបង្កើតខ្សែស្រឡាយបានទេ បើម្នាក់ក្នុងចំណោមឪពុកម្ដាយរស់នៅរដ្ឋខុសគ្នា?

បាន។ ឪពុក ឬម្ដាយរស់នៅរដ្ឋផ្សេងគ្នាអាចចុះហត្ថលេខាការទទួលស្គាល់នូវខ្សែស្រឡាយបាន។ រដ្ឋផ្សេងធ្វើការជាមួយ DCS ដើម្បីទទួលដីកាខ្សែស្រឡាយសម្រាប់កុមារដែលកើតក្នុង និងក្រៅរដ្ឋវ៉ាស៊ីនតោន។

## តើនរណាអាចជួយខ្ញុំបង្កើតខ្សែស្រឡាយ ឬឆ្លើយសំណួររបស់ខ្ញុំ?

- ទូរស័ព្ទទៅ 800-442-KIDS (5437) ឬមើលខាងខ្នងនៃខិត្តប័ណ្ណនេះសម្រាប់លេខទូរស័ព្ទរបស់ការិយាល័យ DCS ដែលនៅជិតអ្នកបំផុត។
- និយាយទៅកាន់មេធាវី។
- ទូរស័ព្ទទៅ CLEAR (ការអប់រំស្របច្បាប់ ដំបូន្មាន និងប្រព័ន្ធយោងដែលបានសម្របសម្រួល) តាមលេខ 888-201-1014។
- ប្រសិនបើអ្នករស់នៅក្នុងខោនធី King ទូរស័ព្ទទៅសមាគមវិជ្ជាជីវៈមេធាវីខោនធី King តាមលេខ 206-623-2551 ដើម្បីសួរអំពីជំនួយផ្នែកច្បាប់ដែលមានតម្លៃទាប។

## ការិយាល័យ DCS

| | |
|---|---|
| Everett | 800-729-7580<br>425-438-4800 |
| Kennewick | 800-345-9981<br>509-374-2000 |
| Olympia | 800-345-9964<br>360-664-6900 |
| Seattle | 800-526-8658<br>206-341-7000 |
| Spokane | 800-345-9982<br>509-363-5000 |
| Tacoma | 800-345-9976<br>253-597-3700 |
| Vancouver | 800-345-9984<br>360-696-6100 |
| Wenatchee | 800-535-1113<br>509-886-6800 |
| Yakima | 800-441-0859<br>509-249-6000 |
| ទីស្នាក់ការកណ្ដាល | 800-457-6202<br>360-664-5000 |
| អ៊ីម៉ែល | dcs-cru@dshs.wa.gov |

Washington State
Department of Social
& Health Services

*Transforming lives*

DSHS 22-586 CA (Rev. 1/19) Cambodian